ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ០៥ អយក.សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារតាមដាន ប្រមូលព័ត៌មាន និងឆ្លើយតបនឹងសំណូមពរក្នុងបណ្ដាញទំនាក់ទំនងសង្គមផ្លូវការរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសេចក្ដីប្រកាសព័ត៌មានលេខ ០១/១៦ សប្រក.ពបហ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ របស់អង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្ដីណែនាំ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារតាមដាន ប្រមូលព័ត៌មាន និងឆ្លើយតបនឹងសំណូមពរក្នុងបណ្តាញទំនាក់ទំនងសង្គមផ្លូវការ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **គឹម សេដ្ឋានី** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **រស់ សាលីន** | នាយកខុទ្ទកាល័យ | អនុប្រធាន |
| ៣-ឯកឧត្តម | **ហ្វូ ឈុនគ្រី** | អគ្គាធិការរង | អនុប្រធានប្រចាំការ |
| ៤-លោក | **នៀ សុផន** | ប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធាន |
| ៥-លោក | **ទេព តិយ្យោរិទ្ធ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | **ម៉ៅ ម៉េងឡុង** | ប្រធាននា.បណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ៧-លោក | **អ៊ឹង ម៉ៅហុក** | ប្រធាននា.មធ្យមសិក្សាចំណេះទូទៅ | សមាជិក |
| ៨-លោក | **អេ សៀម** | ប្រធាននា.អភិវឌ្ឍកម្មវិធីសិក្សា | សមាជិក |
| ៩-លោក | **គង់ តូមីកា** | ប្រធាននាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ១០-លោក | **ចាប សោភ័ណ** | ប្រធាននា.ទវអ | សមាជិក |
| ១១-លោក | **ម៉ៅ សំអេង** | អធិការ នៃអ.រ.ហ | សមាជិក |
| ១២-លោក | **ហាន ឌីវីន** | ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ១៣-លោក | **សុក ថា** | ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា | សមាជិក |

ក្រុមការងារនេះ អាចបន្ថែមសមាជិកតាមការចាំបាច់។

ក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

**ប្រការ ២.-**

ក្រុមការងារនេះ មានអនុក្រុមការងារបច្ចេកទេសជាសេនាធិការក្នុងការតាមដានជាប្រចាំថ្ងៃ ប្រមូលព័ត៌មាន វិភាគ បូកសរុបរបាយការណ៍ និងសុំគោលការណ៍សម្រេចពីក្រុមការងារក្នុងការឆ្លើយតបឱ្យបានទាន់ពេលវេលាតាមសំណូមពរនានា ដែលបានលើកឡើងក្នុងបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ហ្វូ ឈុនគ្រី** | អគ្គាធិការរង | ប្រធាន |
| ២-លោក | **ឡុង សុខត្ថិ** | អនុប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធាន |
| ៣-លោកស្រី | **ទេព ស៊ីណាត** | ប្រធានលេខាធិការដ្ឋានអគ្គ.យុវជន | អនុប្រធាន |
| ៤-កញ្ញា | **សេង ស៊ីណែត** | មន្ត្រីនា.ព័ត៌មាន និងកិច្ចការអាស៊ាន | អនុប្រធានប្រចាំការ |
| ៥-លោក | **ធឿន រតនា** | ប្រធានលេខាធិការដ្ឋានអគ្គ.គ.ជ | សមាជិក |
| ៦-លោក | **ហែម សោរឧុឌ្ឍ** | ប្រធានការិ.នៃមជ្ឈ.ជាតិហ្វឹកហ្វឺនកីឡា | សមាជិក |
| ៧-លោក | **ភាន់ ពុទ្ធី** | អនុប្រធានការិ.នា.បឋមសិក្សា | សមាជិក |
| ៨-លោក | **សុខ សុខសាន្ត** | អនុប្រធានការិ.នា.ឧត្តមសិក្សា | សមាជិក |
| ៩-លោក | **សេង ស្រៀ** | អនុប្រធានការិ.អ.រ.ហ | សមាជិក |

១០-លោក **អ៊ុក សារ៉ាត់** អនុប្រធានការិ.នាយកដ្ឋានហិរញ្ញវត្ថុ សមាជិក
១១-លោក **មឹង វាសនា** អនុប្រធានការិ.នា.មចទ សមាជិក
១២-លោក **គីង សុធីណា** អនុប្រធានការិ.នា.ទវអ សមាជិក
១៣-លោក **អ៊ឹម លីណា** មន្ត្រីខុទ្ទកាល័យ សមាជិក
១៤-លោក **ភាត់ រចនា** មន្ត្រីនាយកដ្ឋានឧត្តមសិក្សា សមាជិក
១៥-លោក **នៃ ភក្តជា** មន្ត្រីលេខាធិការដ្ឋានអគ្គនា.អប់រំ សមាជិក

អនុក្រុមការងារបច្ចេកទេសនេះ អាចបន្ថែមសមាជិកតាមការចាំបាច់។

អនុក្រុមការងារបច្ចេកទេសនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

**ប្រការ ៣.-**

ក្រុមការងារមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ជំរុញការប្រើប្រាស់គេហទំព័រ https//www.facebook.com/hunsencambodia របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- តាមដាន ប្រមូលព័ត៌មានពីផេកហ្វេសប៊ុកសម្តេចតេជោនាយករដ្ឋមន្ត្រី ដើម្បីចងក្រង បូកសរុបវិភាគ និងរៀបចំនូវរបាយការណ៍ពាក់ព័ន្ធជាមួយវិស័យអប់រំ យុវជន និងកីឡា ព្រមទាំងសុំគោលការណ៍សម្រេចពីថ្នាក់ដឹកនាំក្រសួង ក្នុងការឆ្លើយតបឱ្យបានទាន់ពេលវេលាតាមសំណូមពរនានាដែលបានលើកឡើង
- តាមដាន ប្រមូលព័ត៌មាន និងដោះស្រាយបញ្ហាអសកម្មមួយចំនួនក្នុងវិស័យអប់រំដែលបានលើកឡើងដោយសាធារណមតិក្នុងផេកហ្វេសប៊ុក សម្តេចតេជោនាយករដ្ឋមន្ត្រី
- រាយការណ៍ជាប្រចាំរៀងរាល់ថ្ងៃ ជូនថ្នាក់ដឹកនាំក្រសួងអំពីលទ្ធផលការងាររបស់ក្រុមការងារពិសេសព័ត៌មានមួយចំនួនដែលត្រូវសុំយោបល់សម្រេចពីឯកឧត្តមរដ្ឋមន្ត្រីមុននឹងឆ្លើយតប
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន។

**ប្រការ ៤.-**

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

ថ្នាក់ដឹកនាំក្រសួង នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០១៦ (ហត្ថលេខា)

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល** :
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ថ្នាក់ដឹកនាំក្រសួង
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
 «ដើម្បីជូនជ្រាប»
- ដូចប្រការ៥ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ